**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាសកម្មភាពជនពិការ**
**លេខ:** ០០៧.កសព.ប្រក

# ប្រកាស
# ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ
## នៃក្រុមប្រឹក្សាសកម្មភាពជនពិការ ថ្នាក់រាជធានី ខេត្ត

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/០០៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ

**ប្រការ ១.-**

ប្រកាសនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ ថ្នាក់រាជធានី ខេត្ត ដែលសរសេរជាអក្សរកាត់ថា **ក.ស.ជ.រ.ខ.** ជាយន្តការសម្របសម្រួលនិងពិគ្រោះយោបល់លើបញ្ហាពិការភាពនៅថ្នាក់រាជធានី ខេត្ត ។

**ប្រការ ២.-**

សមាសភាព **ក.ស.ជ.រ.ខ.** រួមមាន៖

| | | |
|---|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | | ប្រធានកិត្តិយស |
| - អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ដែលជាសមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការ | | ប្រធាន |
| - ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត | | អនុប្រធាន |
| - ស្នងការនៃស្នងការដ្ឋាននគរបាល រាជធានី ខេត្ត | | អនុប្រធាន |
| - មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង រាជធានី ខេត្ត | | អនុប្រធាន |
| - មេបញ្ជាការកងរាជអាវុធហត្ថ រាជធានី ខេត្ត | | អនុប្រធាន |
| - ប្រធានមន្ទីរសុខាភិបាល រាជធានី ខេត្ត | | អនុប្រធាន |
| - តំណាងជនពិការ ដែលជាជនពិការ | | អនុប្រធាន |
| - អនុប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីរពាណិជ្ជកម្ម រាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីរផែនការ រាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីរព័ត៌មាន រាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូន រាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីរទេសចរណ៍ រាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីរកិច្ចការនារីរាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត | ១រូប | សមាជិក |
| - អនុប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ រាជធានី ខេត្ត | ១រូប | សមាជិក |
| - តំណាងសាខាកាកបាទក្រហមកម្ពុជា រាជធានី ខេត្ត | ១រូប | សមាជិក |
| - តំណាងគណៈកម្មការសកម្មភាពកំចាត់មីន រាជធានី ខេត្ត | ១រូប | សមាជិក |
| - តំណាងអង្គការជនពិការ ដែលជាជនពិការ (បុរស២រូបនិងស្ត្រី២រូប) | ៤រូប | សមាជិក |

- តំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការក្នុងវិស័យពិការភាព ១រូប សមាជិក
- តំណាងនិយោជក ១រូប សមាជិក
- អភិបាលរងនៃគណៈអភិបាលខណ្ឌ ស្រុក/ក្រុងនីមួយៗ ១រូប សមាជិក
- លេខាធិការនៃលេខាធិការដ្ឋាន **គ.ស.ជ.រ.ខ.** សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងរបស់ **គ.ស.ជ.រ.ខ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់សាលារាជធានី ខេត្ត។

**ប្រការ ៣.-**

**គ.ស.ជ.រ.ខ.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្មនៅថ្នាក់រាជធានី ខេត្ត
- ជួយរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រដែលមានការពាក់ព័ន្ធទៅនឹងពិការភាព និងការស្តារលទ្ធភាពពលកម្មនៅថ្នាក់រាជធានី ខេត្ត
- ជួយជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្មនៅថ្នាក់រាជធានី ខេត្ត
- លើកសំណើជូនក្រុមប្រឹក្សាសកម្មភាពជនពិការ ដើម្បីកែសម្រួល បំពេញបន្ថែម ធ្វើវិសោធនកម្ម គោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាព
- តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាពនៅថ្នាក់រាជធានី ខេត្ត
- ទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិដើម្បីផ្លាស់ប្តូរបទពិសោធន៍ កៀរគរប្រភពធនធានទាំងក្នុងនិងក្រៅប្រទេស
- រៀបចំទិវាជនពិការជាតិ ទិវាជនពិការអន្តរជាតិ និងទិវាជនពិការផ្សេងៗទៀតនៅថ្នាក់រាជធានី ខេត្ត
- ជួយក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពទាក់ទងនឹងពិការភាព
- ដឹកនាំ ចាត់ចែង អនុវត្ត និងធ្វើរបាយការណ៍បូកសរុបលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការនៅថ្នាក់រាជធានី ខេត្ត
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពជនពិការនៅថ្នាក់រាជធានី ខេត្តជូនក្រុមប្រឹក្សាសកម្មភាពជនពិការ
- ទទួលសំណើទាក់ទងនិងពិការភាព
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាសកម្មភាពជនពិការប្រគល់ជូន។

**ប្រការ ៤.-**

**គ.ស.ជ.រ.ខ.** ត្រូវធ្វើការប្រជុំយ៉ាងតិច២(ពីរ)ដង ក្នុង១(មួយ)ឆ្នាំ។ ក្នុងករណីចាំបាច់ **គ.ស.ជ.រ.ខ.** អាចធ្វើការប្រជុំវិសាមញ្ញបានតាមការអញ្ជើញរបស់ប្រធាន **គ.ស.ជ.រ.ខ.**។

**ក.ស.ជ.រ.ខ.** ត្រូវធ្វើការបូកសរុបរបាយការណ៍ប្រចាំឆ្នាំអំពីលទ្ធផល នៃការអនុវត្តសកម្មភាពការងារ និងអនុសាសន៍ដែល **ក.ស.ជ.រ.ខ.** ត្រូវដាក់ជូនក្រុមប្រឹក្សាសកម្មភាពជនពិការ។

ប្រធាន **ក.ស.ជ.រ.ខ.** ជាប្រធាននៃរាល់កិច្ចប្រជុំ។ ប្រសិនបើប្រធានអវត្តមាន ប្រធានត្រូវផ្ទេរសិទ្ធិជូនអនុប្រធាន។

**ក.ស.ជ.រ.ខ.** អាចអញ្ជើញអ្នកជំនាញពាក់ព័ន្ធឲ្យចូលរួមក្នុងអង្គប្រជុំបាន។

**ប្រការ ៥.-**

**ក.ស.ជ.រ.ខ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ននានា តំណាងអង្គការមិនមែនរដ្ឋាភិបាល តំណាងជនពិការដែលជាជនពិការ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍តាមការចាំបាច់។

**ប្រការ ៦.-**

របៀបរបបនៃការប្រជុំរបស់ **ក.ស.ជ.រ.ខ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ក.ស.ជ.រ.ខ.**។

**ប្រការ ៧.-**

**ក.ស.ជ.រ.ខ.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួនដើម្បីបំពេញការងារ។

**ប្រការ ៨.-**

**ក.ស.ជ.រ.ខ.** មានលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានទីតាំងនៅក្នុងសាលារាជធានី ខេត្ត។

**ប្រការ ៩.-**

លេខាធិការដ្ឋាន **ក.ស.ជ.រ.ខ.** ដឹកនាំដោយលេខាធិការមួយរូបនិងមានលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលតែងតាំងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

លេខាធិការដ្ឋាន **ក.ស.ជ.រ.ខ.** មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមុខងារសាធារណៈដែលមានស្រាប់របស់សាលារាជធានី ខេត្ត និងអាចប្រើមន្ត្រីជាប់កិច្ចសន្យា និងជំនួយការ អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនតាមការចាំបាច់។

**ប្រការ ១០.-**

លេខាធិការដ្ឋាន **ក.ស.ជ.រ.ខ.** មានតួនាទីនិងភារកិច្ចជាសេនាធិការជួយដល់ដំណើរការតួនាទីនិងភារកិច្ចរបស់ **ក.ស.ជ.រ.ខ.** ។

**ប្រការ ១១.-**

ការចំណាយសម្រាប់ដំណើរការរបស់ **ក.ស.ជ.រ.ខ.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់សាលារាជធានី ខេត្ត ។

**ក.ស.ជ.រ.ខ.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ ១២.-**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ**

**វង សូត**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- សមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ